**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
**សំណុំរឿង រដ្ឋប្បវេណី**
លេខៈ ៣១
ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ២០០៣
**សាលដីកា**
លេខៈ ២៧៣
ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៣

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០០៣ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម .......... ជាប្រធាន
២-លោក ........... ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ............ ជាចៅក្រម
៥-លោក ............ ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**

-លោក ................

**តំណាងមហាអយ្យការ**

-លោក ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៤៨(ង)ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០២ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៥៧៧ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ៈ

-រវាងដើមចោទឈ្មោះ វដល (ជាចុងបណ្តឹងសាទុក្ខ ភេទស្រី អាយុ៣៩ឆ្នាំ មុខរបរចាងហ្វាងផលិតកម្មច័ន្ទរះ ទីលំនៅផ្ទះលេខ៥២ សង្កាត់អូឡាំពិក ខ័ណ្ឌចំការមន ក្រុងភ្នំពេញ។ ឪពុកឈ្មោះ ឯក ណន( រ) ម្តាយឈ្មោះយុយ សំអឿន (ស) ប្តីឈ្មោះមាស ប៊ុនឡាប មានកូន០៥នាក់។

- និងចុងចម្លើយឈ្មោះ យអវដ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៥ឆ្នាំ របរកស៊ីប្រធានក្រុមហ៊ុនហ្វីការី ទីលំនៅសព្វថ្ងៃផ្ទះលេខ៤៨E0 លេខ១៩ ក្រុម៣២ សង្កាត់ផ្សារ កណ្តាល២ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះយស់ ទូនលី "ស" ម្តាយឈ្មោះ ស្រី គាន "រ" ប្តីឈ្មោះ ម៉េង ផ្លោករស្មី ។

***កម្មវត្ថុ*** ប្តឹងទាមទារប្រាក់ចំនួន១៤.៥០០ដុល្លារអាមេរិក ។

បានឃើញបណ្តឹងសាទុក្ខលេខ១២៧ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ របស់ឈ្មោះ ផាត់ ពៅស៊ាង ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៤៨(ង) ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៣ របស់តុលាការ កំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០០ របស់ឈ្មោះវដល ថា ខ្លួនប្តឹងសុំ ទាមទារប្រាក់ចំនួន ១៤.៥០០ដុល្លាអាមេរិក ពីឈ្មោះយអវដ ទាមទារជំងឺចិត្ត និងថ្ងៃខាតបង់ ពេលវេលា ១០.០០០ដុល្លាអាមេរិក ដោយហេតុថាៈ ខ្លួនបានទទួលរត់ការទំនិញឲ្យឈ្មោះ យស់ អែនវ៉ាន់ដា ហើយ ប៉ុន្តែឈ្មោះនេះពុំព្រមសងខ្លួន ពុំព្រមបង់ប្រាក់ផ្លែឈ្នួលរត់ការឲ្យខ្លួន ។ ក្នុងរឿងនេះ បើឈ្មោះយអវដ នៅតែរឹងរូសកុំព្រមសង ខ្លួនប្តឹងសុំរឹបអូសទំនិញចំនួន

០៨កុងទែន័រ ដើម្បីលក់ឡាយឡុងសងប្រាក់ឲ្យខ្លួន និងសុំឲ្យដាក់គុកបង្ខំរូបកាយ ករណីរឹងរូសពុំព្រមសង ។

បានឃើញដីកាសំរេចកិច្ចការប្រញាប់លេខ១៦ប្រ•ធ• ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០០របស់ តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងកិច្ចការប្រញាប់ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០០ របស់ដើម ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ហាមឃាត់មិនឲ្យឈ្មោះយអវដ លក់ដូរ ផ្ទេរសិទ្ធិ បញ្ចាំ ធ្វើអំណោយទំនិញមួយកុងតេន័រលេខ MAEU 8066383 ទុកជាបណ្តោះអាសន្ន រង់ចាំតុលាការសម្រេចដល់រឿងអង្គសេចក្តី ។

៣-បង្គាប់ឲ្យដើមចោទបង់ប្រាក់ប្រដាប់ក្តីចំនួន ៤០០០៛ គឺពន្ធចុះបញ្ជី និងពន្ធហ្នឹងចំនួន១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ២.០០០រៀល សរុប៤០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ដែលដើមចោទបានបង់ទុកជាស្រេច។

៤-ដីកាសម្រេចនេះ មានអានុភាពអនុវត្តភ្លាមៗ ទោះបីជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ។

៥-ដីកាសម្រេចនេះ ជំនុំជំរះចំពោះមុខគួភាគី សម្រេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៧•ធ៉ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០១ របស់ តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០០ របស់ដើមចោទទុកជាត្រឹម ត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-បង្គាប់ឲ្យឈ្មោះយស អែនវ៉ាន់ដា ប្រគល់ទំនិញមួយកុងតេន័រលេខMAEU 8139263 ជំនួសថ្លៃឈ្នួលរត់ការឲ្យ ទៅដើមចោទឈ្មោះ វដល តែតម្រូវឲ្យ ឈ្មោះវដល បង់ពន្ធទំនិញនិង បង់ផែស្តុកខ្លួនឯង តាមការព្រមព្រៀងរបស់គួភាគី ។ បើឈ្មោះយស់ អែន វ៉ាន់ដា គ្មានទំនិញប្រគល់ឲ្យដើមចោទទេ ត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុងបើរឹងរុះត្រូវ ដាក់គុកបង្ខំដល់រូបកាយតាមច្បាប់ស្តីពីនីតិវិធី អនុវត្តសាលក្រមរដ្ឋប្បវេណី ។

៣-អោយឈ្មោះវដល បន្តរត់ការទំនិញនៅសល់ចំនួន០៤កុងតេន័រទៀត គឺកុងតេន័រលេខMAEU 8 126651 , ESTU 767367, MAEU 8066383 , APMU 8025583 រហូតចប់សព្វគ្រប់ ។

៤-ឲ្យឈ្មោះវដល ប្រគល់ឯកសារដើមមានវិគីយប័ត្របង់ប្រាក់រួចចំនួន ០២កុងតេន័រ មានលេខ MAEU 8066383 និង APMU 8025380 និងច្បាប់ក្រុមហ៊ុនមកឈ្មោះ យស អែនវាន់ដា តែឱ្យឈ្មោះយស អែនវ៉ាន់ដា ប្រគល់Invoice និងលិខិតបង់ថ្លៃឈ្នួលកប៉ាល់មកឱ្យ ឈ្មោះវដលវិញ ។

៥-បង្គាប់ឲ្យឈ្មោះយស អែនវាន់ដា បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី និងពន្ធ ហ្នឹងចំនួន១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥០០០៛ សរុប ៧.០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់៧០០០៛ ដែលដើមចោទបានបង់ទុកជាស្រេច ។ កាលបើហួសកំណត់ឧទ្ធរណ៏បង្គាប់ឱ្យឈ្មោះយអវដ សងប្រាក់៧.០០០៛ ទៅឈ្មោះវដល វិញ ។

៦-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខក្នុងចម្លើយ បើកផ្លូវប្តឹងទាស់ និង ផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ១៤•ធ• ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០១ របស់ឈ្មោះយស អែនវាន់ដា ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១៧•ធ•ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញ

ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១២០"ង" ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០១ របស់ឈ្មោះ យស់ អែនវ៉ាន់ដា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយទាស់ខុសនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ១៧"ធ"ចុះថ្ងៃទី១០ ខែឧសភាឆ្នាំ២០០១របស់ តុលាការក្រុងភ្នំពេញទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២,៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល និងលើអាជ្ញាធរតុលាការ ៥,០០០៛ សរុប១៣.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខចុងបណ្តឹងឧទ្ធរណ៍ កំបាំងមុខដើមបណ្តឹងឧទ្ធរណ៍ ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ០៤ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០២ របស់លោកមេធាវីផាត់ ពៅស៊ាង ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ១២០"ង" ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤៨"ង" ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០២ របស់សាលា ឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេច ដូចតទៅៈ

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី ១០ខែ មករា ឆ្នាំ ២០០២ របស់លោកមេធាវីផាត់ ពៅស៊ាង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ ១២០ "ង" ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ទុកជាបានការ ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងឱ្យ ដើមបណ្តឹងទាស់លោកផាត់ ពៅស៊ាង ចំពោះមុខចុងបណ្តឹងទាស់អ្នកស្រីវដល ។ បើកផ្លូវប្តឹង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១២៧ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ របស់ឈ្មោះ ផាត់ពៅស៊ាង ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៤៨"ង" ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ សាលដីកាសាលាឧទ្ធរណ៍ដែល បានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទម្រង់ និង គតិច្បាប់ហើយ ។ សូមក្រុមប្រឹក្សា ជំនុំជំរះសំរេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះយស់ អែនវណ្ណដា ជាម្ចាស់បណ្តឹងសាទុក្ខ៖ នៅពេលសវនាការ សាលាឧទ្ធរណ៍បានសំរេចអោយខ្លួនសងទំនិញទៅឱ្យភាគីអ្នកស្រីវដល នោះខ្លួនមិនសុខ ចិត្តទេ ។ ទំនិញទាំងអស់នោះត្រូវបានគេចាប់ក្នុងផែក្រុងព្រះសីហនុ ។ សាលក្រមចេញមកក៏រឹបអូស ទ្រព្យសម្បត្តិខ្លួន ខ្លួនមានការភ័យខ្លាចសុំឱ្យតុលាការកំពូលរកយុត្តិធមិឱ្យខ្លួនផង ។ ដោយភាគីនាង វណ្ណដាលីន តែងតែព្យាបាទខ្លួនរហូតមិនដែលដោះលែងខ្លួនម្តងណា

ឡើយ ។ ទំនិញគេៗមិនបានដឹក លុយក៏ខាតបង់ទៀត ។ ២កុងតេន័រ ខ្លួនបានទូទាត់រួចរាល់អស់ហើយ នៅសល់៨កុងតេន័រ នៅកំពង់ ផែក្រុងព្រះសីហនុ ខ្លួនជាអ្នកដោះស្រាយជាមួយតុលាការក្រុងព្រះសីហនុ។ ម្យ៉ាងទៀតភ្នាក់ងារគយបានរឹបអូសយកលក់ឡាយឡុងអស់ហើយ ។ សរុបសេចក្តីមកខ្លួនមិនសុខចិត្តសងប្រាក់ទៅអ្នកស្រី
វេលល ទេ ការដាក់គុកបង្ខំរូបរាងកាយខ្លួនក៏មិនសុខចិត្តដែរ ព្រោះនាងវេលល មិនបានបំពេញ តួនាទីដឹកទំនិញឲ្យខ្លួនគ្រប់ចំនួនឡើយ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ វេលល ( ជាចុងបណ្តឹងសាទុក្ខ )នៅពេលសវនាការថា ៖ ខ្លួនបានដឹកទំនិញឲ្យអ្នកស្រីយអវេដ ដោយមានចុះកិច្ចសន្យាត្រឹមត្រូវៈ

+កិច្ចសន្យាទីមួយ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៩៨ ៥កុងតេន័រ កំរៃជើងសារ ៦.៥០០ ដុល្លាអាមេរិក គាត់បានប្រគល់ឱ្យខ្លួន២.០០០ដុល្លាអាមេរិក ។

+ កិច្ចសន្យាទី២ ៥កុងតេន័រ កំរៃជើងសារ ១០.០០០ដុល្លាអាមេរិក ។ ខ្លួនបាននាំទំនិញគ្រប់១០កុងតេន័រ ហើយដឹកលើកទីមួយឡានកាត់ត ឯកឧត្តមថ្នាក់កំពូលជួយសំរួលអនុវត្តហើយកំហុសនេះមិនមែនជាកំហុសរបស់ខ្លួនទេ ៨កុងតេន័រគាត់មិនទាន់បានបង់ពន្ធទេ ។ សូមតុលាការ សម្រេចទៅតាមច្បាប់ដែលខ្លួនបានបំពេញកាតព្វកិច្ចគ្រប់គ្រាន់ហើយច្បាប់គិតយ៉ាងណាតុលាការសម្រេច ចុះ ។ ខ្លួនសុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក សុខ ដា ជាមេធាវីការពារឈ្មោះ យស អែនវ៉ាន់ដា នៅពេលសវនាការថា តាមកិច្ចសន្យាចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៩៨ និងកិច្ចសន្យាដឹកទំនិញ ការដឹកទំនិញពីក្រុងព្រះសីហនុមកភ្នំពេញកូនក្តីខ្លួនពុំបានទទួលលទ្ធិផលទេ ។ទំនិញទាំងនោះត្រូវគេលក់ឡាយឡុងអស់ទៅហើយនេះ ជាកំហុសរបស់អាជ្ញាធរគយ ។ សរុបមកភាគីអ្នកស្រីវេលល ប្តឹង កូនក្តីខ្លួន គឺពុំត្រឹមត្រូវទេ អាស្រ័យហេតុនេះខ្លួនសំណូមពរសុំបដិសេធសាលក្រមតុលាការក្រុងភ្នំពេញ បដិសេធសាលដីកាសាលាឧទ្ធរណ៍ និងសុំមោឃភាពកិច្ចសន្យាចុះថ្ងៃទី០៥ ខែមករាឆ្នាំ១៩៩៨។
សូមក្រុមប្រឹក្សាជំនុំជំរះបង្វិលសំណុំរឿងនេះ ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីចុងចម្លើយ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១២៧ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ របស់លោក ផាត់ ពៅស៊ាង មេធាវីអ្នកស្រីយស់ អែនវ៉ាន់ដា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើក រឿងនេះមកជំនុំជំរះនបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី

- យល់ឃើញថា ការដែលតុលាការក្រុងភ្នំពេញ ក៏ដូចជាសាលាឧទ្ធរណ៍ដែរ ដែលបានសម្រេចឱ្យអ្នកស្រីយស់ អែនវាន់ដា ប្រគល់CONTAINER មួយជូនអ្នកស្រីវេលល ហើយតម្រូវឲ្យ អ្នកស្រីវេលល រត់ការយក CONTAINER ៤ គ្រឿងទៀត ពីកំពង់ផែកំពង់សោមមកប្រគល់ឱ្យអ្នកស្រីយស់ អែនវ៉ាន់ដា នៅក្នុងឃ្លាំងរបស់អ្នកស្រីព្រមជាមួយឯកសារក្រុមហ៊ុនរបស់អ្នកស្រីផង នោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះCONTAINER ទាំង៥នេះត្រូវបានរឹបអូសលក់ឡាយឡុងដោយ អង្គការគយរួចទៅហើយ ហើយសាលាឧទ្ធរណ៍ពុំទាន់បានពិចារណា និង ស្រាវជ្រាវថាការដែលមិន

អាចអនុវត្តកាតព្វកិច្ចតាមការព្រមព្រៀងនេះបាន បណ្តាលមកពីកំហុសរបស់ភាគីណា ?

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៤៨"ង" ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០២ របស់ សាលាឧទ្ធរណ៍ ដែលបានសម្រេច សេចក្តីមកនេះមានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តីចំពោះមុខគូភាគី

១- ទទួលបណ្តឹងសាទុក្ខលេខ១២៧ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០២ របស់លោកមេធាវី ផាត់ ពៅស៊ាង តំណាងឲ្យឈ្មោះយអវេដ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទុកជាមោឃសាលដីការដ្ឋប្បវេណីលេខ៤៨"ង"ចុះថ្ងៃទី០១ខែមេសាឆ្នាំ២០០២សាលាឧទ្ធរណ៍ទាំងមូល

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ៣១ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៣ របស់តុលាការ កំពូល ទៅ សាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលដើមចោទបានបង់គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជាវង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី១៨ ខែធ្នូឆ្នាំ២០០៣ និង ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣ ។